ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១១២៣០ កសក

ភ្នំពេញថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៦

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំស្រូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំស្រូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំស្រូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំស្រូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ មានដូចតទៅ ÷

## I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦ ÷

### ១- ការងារដាំដុះ ÷

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៩ ៥៨៦ហ.ត ស្មើនឹង ១០៤,៩៧%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៧ ៦២៩ហ.ត ស្មើនឹង ៥,១៧%។

### ២- ល្បឿនការងារប្រមូលផលស្រូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់)÷

ការងារប្រមូលផលស្រូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ២ ៣១៥ ៧៩៤ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៩ ៥៨៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៦ ៨៥៧ ៨០៧តោន លើសឆ្នាំមុន ៦០៨ ៣៩៨តោន។ ទិន្នផលគិតជាមធ្យម ២,៩៦១តោន/ហ.ត (សប្តាហ៍មុន ២,៩២១តោន/ហ.ត) លើសឆ្នាំមុន ២២១គ.ក្រ/ហ.ត។

## II. ល្បឿនការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់)÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣៦៩ ៣០៤ហ.ត តិចជាងឆ្នាំមុនចំនួន ១០៩ ៣៤៤ហ.តក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន១២ ៥៩៩ហ.តស្មើនឹង ៣,៤១% និងដោយគ្រឿងយន្តចំនួន ៣៥៦ ៧០៥ហ.តស្មើនឹង ៩៦,៥៩%
- សាបបានសរុបចំនួន ៤៤៣ហ.ត តិចជាងឆ្នាំមុនចំនួន ៦៨៨ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ៣០៧ ៥០១ហ.ត ស្មើនឹង ៧០,៨៩%នៃផែនការ ៤៣៣ ៧៥៥ហ.ត តិចជាងឆ្នាំមុន ១១២ ០៩៤ហ.ត មូលហេតុដោយទឹកស្រកយឺតហើយខេត្តខ្លះពុំទាន់បានអនុវត្តនៅឡើយ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៣៨ ៧០៣ហ.ត ស្មើនឹង ៥២,៨៤% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុន ២ ២០៩ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ៥ ៩៣២ហ.ត ស្មើនឹង ៤២,០១% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ១ ៩៧៣ហ.ត។

## IV. សេចក្តីសន្និដ្ឋាន

ជារួមមកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ៨៩,០៨% នៃផ្ទៃដីអនុវត្ត ២ ៥៩៩ ៥៨៦ហត ដែលទទួលបានទិន្នផលគិតជាមធ្យម **២,៩៦១តោន/ហ.ត** និងកំពុងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀតយ៉ាងសកម្ម។ ដោយឡែក ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងអនុវត្តបានស្មើនឹង **៧០,៨៥%** នៃផែនការ ៤៣៣ ៧៥៥ហ.ត។ ក្នុងសប្តាហ៍នេះ ខេត្តបន្ទាយមានជ័យបានជួបគ្រោះភ្លើងឆេះស្រូវក្នុងស្រែដែលមិនទាន់ប្រមូលផលអស់ចំនួន **១៧ហ.ត**។ ជាមួយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះណែនាំដល់អង្គភាពជំនាញ ឱ្យបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រជាកសិករ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងរដូវប្រាំងនេះ ដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ និងរាលដាលឆេះស្រូវជាយថាហេតុ ព្រមទាំងយកចិត្តទុកដាក់រក្សាទឹកទុកសម្រាប់ការដាំដុះដំណាំនារដូវប្រាំងនេះ។ ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វ ដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 210,322 | 2.885 | 606,860 | 85.15 | 26-12-2016 |
| 02 | បាត់ដំបង | 289,567 | 219,907 | 3.084 | 678,185 | 75.94 | 28-12-2016 |
| 03 | កំពង់ចាម | 89,861 | 68,342 | 3.480 | 237,855 | 76.05 | 21-12-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 119,837 | 3.020 | 361,931 | 96.33 | 27-12-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 92,939 | 2.986 | 277,506 | 80.74 | 26-12-2016 |
| 06 | កំពង់ធំ | 215,526 | 197,346 | 2.602 | 513,515 | 91.56 | 26-12-2016 |
| 07 | កំពត | 138,388 | 120,469 | 3.630 | 437,260 | 87.05 | 26-12-2016 |
| 08 | កណ្ដាល | 35,329 | 22,750 | 3.184 | 72,432 | 64.39 | 27-12-2016 |
| 09 | កោះកុង | 10,503 | 10,503 | 2.638 | 27,707 | 100.00 | បញ្ចប់ |
| 10 | ក្រចេះ | 33,072 | 33,072 | 2.746 | 90,816 | 100.00 | បញ្ចប់ |
| 11 | មណ្ឌលគីរី | 23,608 | 23,608 | 2.736 | 64,591 | 100.00 | បញ្ចប់ |
| 12 | ភ្នំពេញ | 10,291 | 7,135 | 2.750 | 19,621 | 69.33 | 21-12-2016 |
| 13 | ព្រះវិហារ | 82,398 | 82,398 | 2.931 | 241,536 | 100.00 | បញ្ចប់ |
| 14 | ព្រៃវែង | 270,111 | 264,343 | 3.026 | 800,015 | 97.86 | 26-12-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 106,455 | 3.123 | 332,459 | 91.78 | 28-12-2016 |
| 16 | រតនគីរី | 26,185 | 26,185 | 2.490 | 65,201 | 100.00 | បញ្ចប់ |
| 17 | សៀមរាប | 186,735 | 169,845 | 2.650 | 450,023 | 90.96 | 27-12-2016 |
| 18 | ព្រះសីហនុ | 16,605 | 13,577 | 2.431 | 33,010 | 81.76 | 28-12-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 28,678 | 2.500 | 71,695 | 100.00 | បញ្ចប់ |
| 20 | ស្វាយរៀង | 168,528 | 158,584 | 2.691 | 426,697 | 94.10 | 27-12-2016 |
| 21 | តាកែវ | 197,444 | 169,027 | 3.340 | 564,584 | 85.61 | 27-12-2016 |
| 22 | ឧត្ដរមានជ័យ | 86,501 | 86,501 | 2.561 | 221,504 | 100.00 | បញ្ចប់ |
| 23 | កែប | 3,597 | 3,506 | 3.247 | 11,384 | 97.47 | 27-12-2016 |
| 24 | ប៉ៃលិន | 5,825 | 5,800 | 2.826 | 16,388 | 99.57 | 26-12-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 74,665 | 3.148 | 235,032 | 95.35 | 23-12-2016 |
| សរុប | | 2,599,586 | 2,315,794 | 2.961 | 6,857,807 | 89.08 | |
| តួលេខសប្ដាហ៍មុន | | 2,599,586 | 2,078,434 | 2.921 | 6,071,255 | 79.95 | |
| តួលេខឆ្នាំ២០១៥ | | 2,561,957 | 2,280,946 | 2.740 | 6,249,409 | 89.03 | |
| ធៀបធៀបឆ្នាំមុន | | 37,629 | 34,848 | 0.221 | 608,398 | 0.05 | |

បានឃើញនិងឯកភាព

ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហ.ត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 22,299 | - | - | 22,299 | 100.00 | 1 | 30 | 21,734 | 21,764 | 121.79 | 26-12-2016 |
| 02 | បាត់ដំបង | 16,400 | 8,641 | - | - | 8,641 | 100.00 | - | - | 8,535 | 8,535 | 52.04 | 28-12-2016 |
| 03 | កំពង់ចាម | 42,000 | 33,088 | 9,453 | 28.57 | 23,635 | 71.43 | 115 | 894 | 28,748 | 29,642 | 70.58 | 21-12-2016 |
| 04 | កំពង់ឆ្នាំង | 30,700 | 14,550 | - | - | 14,550 | 100.00 | 198 | - | 14,352 | 14,352 | 46.75 | 27-12-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 36,428 | - | - | 36,428 | 100.00 | 12 | 142 | 36,286 | 36,428 | 101.19 | 26-12-2016 |
| 07 | កំពត | 7,000 | 5,250 | - | - | 5,250 | 100.00 | - | - | 5,250 | 5,250 | 75.00 | 26-12-2017 |
| 08 | កណ្តាល | 55,800 | 24,371 | 1,048 | 4.30 | 23,323 | 95.70 | - | - | 13,042 | 13,042 | 23.37 | 27-12-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,990 | 1,489 | 9.93 | 13,501 | 90.07 | 21 | 1,191 | 12,833 | 14,024 | 100.17 | 27-12-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | 5 | - | - | 5 | 100.00 | - | - | 3 | 3 | 0.26 | 21-12-2016 |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 57,539 | - | - | 57,539 | 100.00 | - | - | 57,539 | 57,539 | 76.72 | 26-12-2016 |
| 15 | ពោធិ៍សាត់ | 9,000 | 9,235 | - | - | 9,235 | 100.00 | - | - | 8,849 | 8,849 | 98.32 | 28-12-2016 |
| 16 | រតនៈគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 21,440 | - | - | 21,440 | 100.00 | 20 | 80 | 18,675 | 18,755 | 89.63 | 27-12-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 19,285 | - | - | 19,285 | 100.00 | - | - | 17,500 | 17,500 | 87.50 | 27-12-2016 |
| 21 | តាកែវ | 75,000 | 91,772 | 459 | 0.50 | 91,313 | 99.50 | - | - | 51,607 | 51,607 | 68.81 | 27-12-2016 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | 35 | - | - | 35 | 100.00 | - | - | 35 | 35 | 116.67 | 13-12-2016 |
| 24 | ប៉ៃលិន | 1,000 | 101 | | - | 101 | 100.00 | 1 | 36 | 65 | 101 | 10.10 | 26-12-2016 |
| 25 | ត្បូងឃ្មុំ | 10,500 | 10,275 | 150 | 1.46 | 10,125 | 98.54 | 75 | 795 | 9,280 | 10,075 | 95.95 | 23-12-2016 |
| | សរុប | 433,755 | 369,304 | 12,599 | 3.41 | 356,705 | 96.59 | 443 | 3,168 | 304,333 | 307,501 | 70.89 | |
| | តួលេខសប្តាហ៍មុន | 433,755 | 321,556 | 10,647 | 3.31 | 310,909 | 96.69 | 412 | 1,916 | 258,826 | 260,742 | 60.11 | |
| | តួលេខឆ្នាំមុន | 417,325 | 478,648 | 15,349 | 3.21 | 463,299 | 96.79 | 1,131 | 7,831 | 411,764 | 419,595 | 100.54 | |
| | ប្រៀបធៀបឆ្នាំមុន | 16,430 | -109,344 | -2,750 | 0.20 | -106,594 | -0.20 | -688 | -4,663 | -107,431 | -112,094 | | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | 34 | - | 6,250 | 5,046 | - | - | 1,325 | 756 | 120 | 1 | 7,920 | 5,837 | 73.70 |
| 02 | បាត់ដំបង | 460 | - | 74 | - | - | - | 50 | 12 | 960 | 169 | 300 | 51 | 1,770 | 306 | 17.29 |
| 03 | កំពង់ចាម | 1,010 | 150 | 2,021 | 747 | 20 | 38 | 760 | 344 | 2,380 | 2,907 | 150 | 844 | 4,320 | 6,154 | 142.45 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | 281 | - | 90 | 50 | 230 | 107 | 1,860 | 1,140 | 1,800 | 896 | 5,070 | 2,474 | 48.80 |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | 128 | - | 90 | - | 60 | 45 | 345 | 241 | 20 | - | 645 | 414 | 64.19 |
| 07 | កំពត | 200 | - | 8 | - | 135 | 6 | 245 | 6 | 590 | 40 | 255 | 12 | 1,425 | 72 | 5.05 |
| 08 | កណ្តាល | 8,101 | 6,620 | 495 | 480 | 225 | - | 190 | - | 5,056 | 944 | 4,307 | 169 | 17,879 | 1,608 | 8.99 |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 4,169 | 3,939 | - | - | 80 | 60 | 420 | 459 | 40 | 57 | 2,340 | 4,745 | 202.78 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | 5,100 | 5,100 | 200 | - | 10 | - | 790 | 263 | 1,425 | 1,161 | 4,250 | 6,524 | 153.51 |
| 15 | ពោធិ៍សាត់ | 200 | 100 | 100 | - | 850 | 2,354 | 350 | - | 500 | 180 | 300 | 7 | 2,200 | 2,641 | 120.05 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | 275 | - | 2,490 | 780 | 265 | 180 | 2,040 | 700 | 1,850 | 190 | 7,475 | 2,125 | 28.43 |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | 2 | | | 370 | 2 | - |
| 19 | ស្ទឹងត្រែង | 250 | - | 104 | - | - | | - | 36 | 450 | 94 | 500 | 110 | 1,200 | 344 | 28.67 |
| 20 | ស្វាយរៀង | - | - | - | - | 7,100 | 369 | 110 | - | 1,170 | 925 | - | - | 8,380 | 1,294 | 15.44 |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | 36 | 4 | 30 | 14 | 100 | 41 | 200 | 59 | - | - | 480 | 150 | 31.25 |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 4,070 | 3,895 | - | 45 | 400 | 395 | 1,145 | 845 | 490 | 365 | 10,977 | 5,720 | 16,907 |
| | សរុប | 18,713 | 12,595 | 13,232 | 10,270 | 19,521 | 10,400 | 2,585 | 1,228 | 11,350 | 10,195 | 12,067 | 3,693 | 73,249 | 38,703 | 52.84 |
| | តួលេខសប្តាហ៍មុន | 18,713 | 12,595 | 9,853 | 7,577 | 19,521 | 4,026 | 2,585 | 943 | 11,350 | 8,059 | 12,067 | 2,085 | 73,249 | 24,966 | 34.08 |
| | តួលេខឆ្នាំមុន | 10,504 | 188 | 16,003 | 12,449 | 4,174 | 5,647 | 4,116 | 1,498 | 11,804 | 10,661 | 12,100 | 7,103 | 42,698 | 40,912 | 95.82 |
| | ប្រៀបធៀបឆ្នាំមុន | 8,209 | 12,407 | -2,771 | -2,179 | 15,347 | 4753 | -1,531 | -270 | -454 | -466 | -33 | -3,410 | 30,551 | -2,209 | -42.98 |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | 105 | - | 35 | - | | 110 | 140 | 127.27 |
| 02 | បាត់ដំបង | 100 | 3 | | | 100 | 8 | 30 | 16 | - | - | - | - | 230 | 27 | 11.74 |
| 03 | កំពង់ចាម | 790 | 370 | - | - | 30 | 548 | 360 | 196 | - | - | 3,380 | 770 | 4,560 | 1,884 | 41.32 |
| 04 | កំពង់ឆ្នាំង | 80 | 49 | - | - | 760 | 351 | 60 | 31 | 10 | 12 | 60 | 7 | 970 | 450 | 46.39 |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | - | - | - | - | - | - | 39 | - | - | - | - | 199 | 39 | 19.60 |
| 07 | កំពត | 205 | - | - | - | 30 | - | 235 | 8 | - | - | - | - | 470 | 8 | 1.70 |
| 08 | កណ្តាល | 96 | - | 50 | - | 150 | - | 442 | 75 | - | - | - | - | 738 | 75 | 10.16 |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 172 | - | - | - | - | 110 | 94 | - | - | - | 892 | 230 | 1,158 | 503.48 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | 101 | - | | 1,025 | - | 175 | 40 | - | | - | | 1,330 | 141 | 10.60 |
| 15 | ពោធិ៍សាត់ | 550 | 11 | 50 | - | 200 | - | 720 | 37 | - | | - | | 1,520 | 48 | 3.16 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | - | 10 | 10 | 210 | - | 405 | 105 | - | - | - | - | 625 | 115 | 18.40 |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | 20 | - | | | | | 30 | | | | 10 | - | 60 | |
| 20 | ស្វាយរៀង | - | - | - | - | - | - | 523 | - | - | - | - | - | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | 11 | - | - | - | - | 30 | 138 | - | | - | | 130 | 149 | 114.62 |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | 115 | - | - | - | 45 | 20 | 25 | - | - | 1,340 | 1,140 | 1,590 | 1,325 | 83.33 |
| | សរុប | 3,624 | 923 | 110 | 15 | 2,616 | 969 | 3,785 | 1,159 | 10 | 47 | 4,780 | 2,819 | 14,121 | 5,932 | 42.01 |
| | តួលេខសប្តាហ៍មុន | 3,624 | 618 | 110 | 15 | 2,616 | 847 | 3,785 | 951 | 10 | 35 | 4,780 | 1,531 | 14,121 | 3,997 | 28.31 |
| | តួលេខឆ្នាំមុន | 3,624 | 1,587 | 1,173 | 712 | 2,789 | 855 | 3,735 | 889 | 80 | 8 | 8,930 | 3,854 | 20,331 | 7,905 | 38.88 |
| | ប្រៀបធៀបឆ្នាំមុន | - | -664 | -1,063 | -697 | -173 | 114 | 50 | 270 | -70 | 39.00 | -4,150 | -1,035 | -6,210 | -1,973 | 3.13 |

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១៦

ប្រធានការិយាល័យស្ថិតិ